អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

ដោយសារតែបញ្ហាសុខភាពដែលធ្វើឲ្យគាត់បារម្ភថា គាត់មិនអាចធ្វើការការពារក្តីឲ្យលោក ខៀវ សំផន រហូតដល់ការកាត់ក្តីបានចប់រួចរាល់នោះ លោកបណ្ឌិត សាយ បូរី បានលាលែងពីមុខតំណែងជាសហមេធាវីខ្មែរការពារក្តីឲ្យលោក ខៀវ សំផន ។ រឿងនេះត្រូវបានសម្រេចថា គឺជាការសមហេតុផលដែល អង្គភាពគាំពារការការពារក្តី (DSS) ត្រូវស្វែងរកមេធាវីខ្មែរថ្មីម្នាក់ តាំងពីពេលឥឡូវនេះទៅដើម្បីឲ្យមេធាវីរូបនោះមានពេលវេលាគ្រប់គ្រាន់ ដើម្បីនឹងរៀបចំការការពារក្តី។

អង្គភាពគាំពារការការពារក្តី (DSS) និង លោកបណ្ឌិត សាយ បូរី បានជួបលោក ខៀវ សំផន ដើម្បីពិភាក្សាគ្នាអំពីការការពារក្តីរបស់គាត់ ហើយសហមេធាវីខ្មែរថ្មីនឹងត្រូវធ្វើការជ្រើសរើសក្នុងពេលឆាប់ៗនេះ។

លោកបណ្ឌិត សាយ បូរី នឹងបន្តធ្វើជាតំណាងឲ្យលោក ខៀវ សំផន នៅក្នុងរយៈពេលនៃការផ្ទេររឿងក្តី ទៅឲ្យសហមេធាវីខ្មែរថ្មី។